**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០៥ សរណន

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំខួបលើកទី៥៧ "ទិវាកុមារអន្តរជាតិ ១ មិថុនា" និងខួបលើកទី៥ "ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា" ឆ្នាំ២០០៦

ក្នុងអំឡុងឆ្នាំ ១៩៤២-១៩៤៤ នៃសង្គ្រាមលោកលើកទី២ ពួកហ្វាស៊ីស្តអ៊ីត្លែបានបង្កវិនាសកម្មកាប់សម្លាប់ស្ត្រី និងកុមារនៅភូមិលីឌីសែ ប្រទេសឆេក និង ភូមិអូរ៉ាឌូ ប្រទេសបារាំង។ វិនាសកម្មនេះបានបង្កឱ្យមានការឈឺចាប់យ៉ាងខ្លាំងក្លាទៅលើប្រជាជនក្នុងពិភពលោក ដែលជាហេតុធ្វើឱ្យប្រទេសជាច្រើនលើពិភពលោកកំណត់យកថ្ងៃ ១ មិថុនា នេះជាទិវាកុមារអន្តរជាតិ។ ទន្ទឹមនេះ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍មួយចំនួន នៅតែបន្តអនុវត្តការប្រើប្រាស់ទម្រង់ពលកម្មធ្ងន់ធ្ងរមកលើកុមារ។ ក្នុងចំណោមកុមារមានចាប់ពីអាយុ ៥ឆ្នាំ ដល់ ១៧ឆ្នាំ ប្រមាណ ២៤៦លាននាក់ ដែលកំពុងធ្វើការងារ ក៏នៅមានកុមារប្រមាណជាង ១០០លាននាក់ ស្ថិតក្នុងទម្រង់ពលកម្មធ្ងន់ធ្ងររួមមាន ទាសករកុមារ ការជួញដូរកុមារ ពេស្យាចារកុមារ កុមារក្នុងជម្លោះប្រដាប់អាវុធ និងការប្រើប្រាស់កុមារស្ថិតក្នុងស្ថានភាពងាយរងគ្រោះ។ ដើម្បីទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ការងារដ៏ធ្ងន់ធ្ងរនេះ អង្គការពលកម្មអន្តរជាតិបានសម្រេចយកថ្ងៃ១២ មិថុនា ជារៀងរាល់ឆ្នាំ ដើម្បីរំលឹកទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ។

ថ្ងៃទី ២០ ខែ វិច្ឆិកា ១៩៨៩ មហាសន្និបាតរបស់អង្គការសហប្រជាជាតិ បានអនុម័តលើអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ឆ្នាំ១៩៩០ សន្និសីទកំពូលពិភពលោកដើម្បីកុមារ បានអនុម័តលើ "គោលដៅពិភពលោកដើម្បីកុមារ" និងបានប្តេជ្ញាចិត្តបង្កើនសុខុមាលភាពកុមារលើគ្រប់វិស័យឱ្យកាន់តែល្អប្រសើរឡើង។ នៅខែឧសភា ឆ្នាំ២០០២ សម័យប្រជុំពិសេសរបស់អង្គការសហប្រជាជាតិស្តីពីកុមារ បានឯកភាពចេញសេចក្តីប្រកាសរួមមួយឈ្មោះ "ពិភពលោកមួយសមស្របសម្រាប់កុមារ" ដែលឯកសារនេះ គឺជាក្របខ័ណ្ឌការងារសម្រាប់រដ្ឋាភិបាល និងដៃគូទាំងអស់ ព្រមទាំងកុមារប្រើប្រាស់ដើម្បីសម្រេចគោលដៅ និងដោះស្រាយការលំបាក ដែលកំពុងកើតមានចំពោះកុមារ។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញឯកសារ**កម្ពុជាដើម្បីកុមារ** ដោយកំណត់បញ្ហាអាទិភាពចំនួនបួនគឺ : មួយ : ការបង្កើនជីវភាពរស់នៅរបស់ស្ត្រី និងកុមារប្រកបដោយសុខភាពល្អ . ពីរ : ការបង្កើនគុណភាពអប់រំ. បី : ការប្រយុទ្ធប្រឆាំង មេរោគអេដស៍/ជម្ងឺអេដស៍ និងបួន :

កិច្ចការពារកុមាររួចផុតពីការរំលោភ ការកេងប្រវ័ញ្ច និងអំពើហិង្សា។ នៅឆ្នាំ២០០៥ កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់រដ្ឋមន្ត្រីតំបន់អាស៊ីបូព៌ា ប៉ាស៊ីហ្វិកលើកទី៧ ស្តីពីកុមារ ដែលបានប្រារព្ធឡើងនៅខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា បានអនុម័តសេចក្តីប្រកាសសៀមរាប-អង្គរ ដែលគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់បណ្តាប្រទេសក្នុងតំបន់ ដើម្បីបោះជំហានទៅមុខ និងធ្វើឱ្យសកម្មសំដៅលើកស្ទួយឱ្យបានប្រសើរឡើងនូវការរស់រានមានជីវិត ការលូតលាស់និងការអភិវឌ្ឍរបស់កុមារ និងកុមារវ័យជំទង់។ ទន្ទឹមនេះដែរ មានកិច្ចប្រជុំជាបន្តបន្ទាប់ថ្នាក់តំបន់ ឬ អនុតំបន់ស្តីពីបញ្ហាជាក់លាក់មួយចំនួនរបស់កុមារ ។

ព្រះរាជាណាចក្រកម្ពុជាធ្លាប់បានជួបប្រទះ និងទទួលរងមហាវិនាសកម្មដ៏ធ្ងន់ធ្ងរ បង្កឡើងដោយរបបប្រល័យពូជសាសន៍ប៉ុលពត ដែលបានធ្វើឱ្យប្រជាជន យុវជន កុមារ បាត់បង់សិទ្ធិជាមនុស្ស បង្ខំឱ្យធ្វើការជាទម្ងន់ រស់នៅយ៉ាងសែនវេទនា ក្លាយជាទាសករ រងនូវទារុណកម្ម និងការកាប់សម្លាប់ដោយអយុត្តិធម៌អស់រាប់លាននាក់។ ក្រោយថ្ងៃ៧ មករា ១៩៧៩ សិទ្ធិរបស់ប្រជាពលរដ្ឋ និងជាពិសេសសិទ្ធិរបស់កុមារនៅកម្ពុជាត្រូវបានយកចិត្តទុកដាក់ ដោយមានចែងច្បាស់ក្នុងរដ្ឋធម្មនុញ្ញ និងកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលស្របទៅតាមអនុសញ្ញាអន្តរជាតិផ្សេងៗដែលពាក់ព័ន្ធកុមារ។ ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពី សិទ្ធិកុមារ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ហើយនៅឆ្នាំ២០០២ បានផ្តល់សច្ចាប័នលើពិធីសារពីរគឺៈ មួយ : ការចូលរួមរបស់កុមារក្នុងជំលោះប្រដាប់អាវុធ, ពីរ : ការជួញដូរកុមារការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសរបស់កុមារ។ នៅឆ្នាំ២០០៥ ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នអនុសញ្ញាលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

ក្នុងគោលដៅដើម្បីអនុវត្តឱ្យបានរឹតតែល្អថែមទៀតនូវសិទ្ធិកុមារ រាជរដ្ឋាភិបាលណែនាំចាត់តាំងទិវាកុមារអន្តរជាតិ ១ មិថុនា និងទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា ឆ្នាំ ២០០៦ ដូចខាងក្រោម :

១- គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់ថ្នាក់ ត្រូវធ្វើកិច្ចសហការគ្នាជាមួយអង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ដៃគូឯកជន និងប្រជាពលរដ្ឋដើម្បីឧបត្ថម្ភគាំទ្រ និងផ្សព្វផ្សាយជូនដល់អង្គភាពក្រោមឱវាទ និងសង្គមជាតិទាំងមូលឱ្យបានជ្រួតជ្រាបអំពីប្រវត្តិនៃទិវាកុមារអន្តរជាតិ ១ មិថុនា និងទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា។

២- ត្រូវរៀបចំពិធីមិទ្ទិញ ឬ ពិធីជួបជុំសំណេះសំណាលជាមួយកុមារ និងមានកម្មវិធីចាត់តាំងកំសាន្តសប្បាយរបស់កុមារនៅក្នុងមូលដ្ឋានរបស់ខ្លួន តាមលទ្ធភាពជាក់ស្តែង។

៣- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ សាលាក្រុងភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ ត្រូវ

សហការរៀបចំមិទិញ និងមានកម្មវិធីកំសាន្តផ្សេងៗសម្រាប់កុមារនៅទីធ្លាសាធារណៈ ឬរមណីយដ្ឋានណាមួយសក្តិសមនៅរាជធានីភ្នំពេញ ឱ្យបានឱឡារិក អធិកអធម ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុង ត្រូវរៀបចំចាត់តាំងអនុវត្តឱ្យបានប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល " ដើម្បីជូនជ្រាប "
- គ្រប់ក្រសួង - ស្ថាប័ន " ដើម្បីសហការអនុវត្ត "
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ